# ពេលស្ងៀត

តើមាននឹងអ្វីកើតឡើង
នៅពេលយើងដឹងខ្លួនថា
យើងរស់នៅក្នុងពេលស្ងៀត?

ហួត សេងគៀ

Samanh EBooks

# មាតិកា

ទំព័រដើម

វត្តមានមនុស្សចោលម្សៀត

និយមន័យមនុស្សចោលម្សៀត

ប្រភេទនៃមនុស្សចោលម្សៀត

មនុស្សចោលម្សៀត និងបទពិសោធន៍

តើខ្ញុំត្រូវធ្វើអ្វីបន្តទៀត?

# ទំព័រដើម

យើងអាចគិតបានល្អនៅពេលយើងនៅម្នាក់ឯង តែនៅពេលយើងនិយាយជាមួយ អ្នកណាម្នាក់ ក៏យើងអាចគិតបានដែរ។ ការគិតរបស់យើង អាចនឹងមិនមាន សណ្តាប់ធ្នាប់ ដូចពេលនៅម្នាក់ឯង តែវាក៏មិនអាក្រក់រហូតដល់ប្រើការមិនកើតដែរ។

ក្រោយពេលធ្វើការពេញមួយថ្ងៃ ខ្ញុំអាចសម្រាកបាន ដោយមានសង្សាររបស់ខ្ញុំនៅ និយាយជាមួយខ្ញុំ។ ពួកយើងនិយាយគ្នាពីរឿងជាច្រើន។ ការនិយាយគ្នានេះ ធ្វើឡើងក្នុងគោលបំណងស្វែងយល់ពីគ្នាឱ្យបានច្រើន ដើម្បីជៀសវាងជម្លោះនៅ ថ្ងៃក្រោយ។ ពួកយើងស្គាល់គ្នាជិត ៥ឆ្នាំហើយ តែមានរឿងខ្លះ ខ្ញុំនៅតែមិនយល់ និងមិនដឹងពីសង្សារខ្ញុំដដែល។

ដោយសារពួកយើងស្គាល់គ្នាយូរ ហេតុនេះ យើងចាប់ផ្តើមបើកចំហរពីរឿងដែល យើងគិតច្រើនជាងមុន។ ការបើកចំហរ មានទាំងផលវិបាក និងផលប្រយោជន៍ របស់វា។ ពេលខ្លះ ពួកយើងឈ្លោះគ្នា ព្រោះនិយាយជ្រុលមាត់ តែអាចមានផ្លូវ ផ្សះផ្សាគ្នាបានវិញ។ អារម្មណ៍ខឹងមួយពេល នៅតែមាន តែពួកយើងស្វែងយល់ពីគ្នា បានច្រើន។

ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ជាថ្ងៃដែលខ្ញុំដឹងរឿងមួយសំខាន់បំផុត។ ខ្ញុំប្រៀប ដូចជាត្រូវគេដកក្រណាត់ចងមុខចេញ ហើយមើលឃើញរឿងជាច្រើនដែលខ្ញុំតែងតែ សង្ស័យពីមុន។

ខ្ញុំ និងសង្សារខ្ញុំជជែកគ្នាពីរឿងការងារ ហើយក៏មានការយល់ខុសពីគ្នាច្រើន។ ខ្ញុំមិន អាចរៀបរាប់បានថាខ្ញុំនិយាយអ្វីខ្លះទេ ព្រោះនេះមិនមែនជាពេលចូលតួ។ ខ្ញុំបានដឹង ថា សង្សាររបស់ខ្ញុំ គិតថាខ្ញុំជាមនុស្សបោលម្សៀត។ គេមិនប្រើពាក្យនេះឱ្យចំទេ ព្រោះវាគ្មានសុជីវធម៌ និងជាការមើលងាយអ្នកដទៃ។ ខ្ញុំអាចយល់បាន ព្រោះខ្ញុំ

ស្គាល់សង្សារខ្ញុំយូរហើយ។ ខ្ញុំក៏ធ្វើជាសួរបញ្ជាក់ ដើម្បីឱ្យគេនិយាយ តែគេក៏ប្តូរប្រធានបទ។ ខ្ញុំអាចដឹងចម្លើយហើយ។

ក្រោយមក ខ្ញុំក៏យកមកគិតមួយយប់។ ខ្ញុំខឹងនឹងអ្វីដែលសង្សារខ្ញុំគិត តែខ្ញុំក៏មានចិត្តមួយទៀតសួរខ្លួនឯងថា តើខ្ញុំពិតជាមនុស្សចោលម្សៀតមែនឬអត់? ខ្ញុំគិតត្រលប់ទៅអ្វីដែលខ្ញុំធ្វើកន្លងមក ឃើញថា ខ្ញុំជាមនុស្សចោលម្សៀតពិតមែន។ ខ្ញុំក៏មិនអាចមានលេសអ្វីខឹងសង្សារខ្ញុំទៀតដែរ។ យើងមិនអាចខឹងគេបានទេ បើសិនជាគេនិយាយត្រូវ។

ខ្ញុំតែងតែចង់ធ្វើអ្វីឱ្យសង្សារខ្ញុំសប្បាយចិត្ត និងភ្ញាក់ផ្អើលលើសមត្ថភាពខ្ញុំជានិច្ច។ ខ្ញុំតែងតែបោកខ្លួនឯងថា អ្វីដែលខ្ញុំអាចធ្វើបាន ជារឿងអស្ចារ្យ តែតាមពិតមិនមែនទេ។ ការសរសេរប្លុក និងសៀវភៅ រួមទាំងការងារដែលខ្ញុំកំពុងធ្វើ ជាភស្តុតាងបញ្ជាក់ថាខ្ញុំជាមនុស្សចោលម្សៀត ដែលលាក់ខ្លួនពីក្រោយអំណួតក្លែងក្លាយប៉ុណ្ណោះ។

តើយើងគួរធ្វើអ្វីខ្លះ ពេលបានដឹងការពិតពីខ្លួនឯងបែបនេះ? បើតាមដំណាក់កាលនៃការទទួលយកការពិតរបស់អ្នកជម្ងឺមហារីក ខ្ញុំមានជម្រើសពីរយ៉ាង។ ទីមួយ គឺឆ្លងម្តងមួយដំណាក់ រហូតដល់ដំណាក់កាលចុងក្រោយ។ ជម្រើសទីពីរ គឺខ្ញុំលោតផ្លោះមកដំណាក់កាលចុងក្រោយតែម្តង ដើម្បីកុំឱ្យខាតពេល។

ដំណាក់កាលទាំងប្រាំនោះ មានដូចជា៖

១ ប្រកែក មិនទទួលយក
២ ខឹង
៣ តថ្លៃ រកលេសឱ្យធូរចិត្ត
៤ កើតទុក្ខ ព្រួយចិត្ត
៥ ទទួលយក

ខ្ញុំមិនចង់ខាតពេល ប្រកែក ឬរកលេសឱ្យខ្លួនឯងទេ ព្រោះខ្ញុំមានហេតុផលគ្រប់គ្រាន់បញ្ជាក់ខ្លួនឯងថា ចោលម្សៀតរួចទៅហើយ។

ខ្ញុំទទួលយកការពិត ទាំងមិនដឹងថាត្រូវធ្វើអ្វីបន្តទៀត។ ការពិត ធ្វើឱ្យមនុស្សឈឺចិត្ត ហើយបើសិនជាការពិតនោះចេញពីមាត់មនុស្សដែលយើងស្រលាញ់ទៀត តើខ្ញុំគួរមានអារម្មណ៍បែបណា?

ខ្ញុំអាចបន្ទោសសង្សារខ្ញុំក៏បាន ឬបន្ទោសខ្លួនឯងក៏បាន ព្រោះខ្ញុំមិនដែលចាប់អារម្មណ៍ពីខ្លួនឯង។ ខ្ញុំថាអ្នកដទៃចោលម្សៀត តែមិនបានមើលឱ្យជ្រៅដល់អ្វីដែលខ្ញុំធ្វើកន្លង។ អ្វីដែលខ្ញុំមាន សុទ្ធតែមិនសំខាន់ និងមិនអាចប្រើបានសម្រាប់អនាគត។ សង្សារខ្ញុំ ប្រាប់ខ្ញុំពីអ្វីដែលខ្ញុំត្រូវតែដឹង។ ខ្ញុំទទួលយកអ្វីដែលខ្ញុំត្រូវតែដឹង។

សៀវភៅនេះ ជាការស្វែងយល់ពីភាពចោលម្សៀតរបស់ខ្ញុំ និងជាការរកផ្លូវចេញដោយខ្លួនឯង។ ខ្ញុំមិនអាចធានាបានទេ ថាវានឹងអាចជួយខ្ញុំបាន។ ខ្ញុំកត់ត្រាអ្វីដែលខ្ញុំគិត នៅក្នុងសៀវភៅនេះ ដើម្បីខ្ញុំអាចមើលឃើញគំនិតខ្លួនឯងកាន់តែច្បាស់។ ខ្ញុំគិតដោយសារការអាន ហើយនៅពេលខ្ញុំអានអ្វីដែលខ្លួនឯងសរសេរ ខ្ញុំនឹងគិតបានកាន់តែច្បាស់។

ខ្ញុំនឹងផ្តល់និយមន័យរបស់មនុស្សចោលម្សៀតឱ្យបានច្បាស់ តាមអ្វីដែលខ្ញុំអាចធ្វើបាន។ ខ្ញុំនឹងផ្តល់វិធីមើលខ្លួនយើងថា ជាមនុស្សចោលម្សៀតឬអត់។ អ្នកទាំងអស់គ្នា អាចយកអ្វីដែលខ្ញុំធ្វើក្នុងសៀវភៅនេះ ទៅសាកល្បងដោយខ្លួនឯង។ គ្មានអ្នកណាចង់ធ្វើជាមនុស្សចោលម្សៀតទេ តែមិនប្រាកដថាអ្នកដែលមិនចង់ទាំងនោះ សុខចិត្តធ្វើគ្រប់យ៉ាងដើម្បីចេញផុតពីភាពចោលម្សៀតដែរ។

សៀវភៅនេះ អាចជាការរំលឹក ដល់អ្នកអានដទៃទៀត (ពិសេស គឺមនុស្សប្រុស) កុំបណ្តោយខ្លួនទៅជាមនុស្សចោលម្សៀតយូរពេក។ ភាពចោលម្សៀតរបស់ខ្ញុំ មិនតូចទេ ហើយខ្ញុំក៏មិនច្បាស់ថា វាមានក្នុងខ្លួនខ្ញុំតាំងពីពេលណាដែរ។

ក្នុងសៀវភៅផ្សេងទៀត ខ្ញុំចែករំលែកចំណេះដឹងដែលខ្ញុំគិតថា មានប្រយោជន៍ តែក្នុងសៀវភៅនេះ ខ្ញុំចែករំលែកភាពចោលម្សៀតរបស់ខ្ញុំ ដើម្បីជាប្រយោជន៍ដល់អ្នកដទៃទៀត។ យើងគ្រាន់តែដឹង និងទទួលស្គាល់ មិនអាចជួយផ្លាស់ប្តូរភាពចោលម្សៀតរបស់យើងទេ។ យើងត្រូវប្រឹងធ្វើគ្រប់យ៉ាងដែលយើងអាចនឹកឃើញ។

រឿងរ៉ាវគ្រប់យ៉ាងដែលកើតឡើងក្នុងជីវិតខ្ញុំ សុទ្ធតែអាចចងក្រងជាសៀវភៅបានទាំងអស់។ រឿងល្អ ឬអាក្រក់ មិនសំខាន់ទេ ឱ្យតែមានអត្ថន័យចំពោះអ្នកណាម្នាក់។ សៀវភៅនេះ ខ្ញុំសរសេរជាពិសេសជូនចំពោះខ្លួនខ្ញុំ។ សម្រាប់អ្នកអានដទៃ អាចអានតាមធម្មតា តែមិនបានទទួលពាក្យពិសេសពីខ្ញុំទេ។

ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៨

# វត្តមានមនុស្សចោលម្សៀត

ការពិតមួយរបស់មនុស្សចោលម្សៀត គឺពួកគេមានចំនួនច្រើនណាស់នៅលើលោកនេះ។ វាមិនមែនជាពាក្យបំភ្លើសរបស់ខ្ញុំទេ។ យើងសាកល្បងមើលនៅកន្លែងធ្វើការ ឬក្នុងថ្នាក់រៀន យើងនឹងឃើញថា មនុស្សជោគជ័យ មានចំនួនតិចជាងមនុស្សចោលម្សៀត។

ថៅកែក្រុមហ៊ុនតែមួយ គ្រប់គ្រងមនុស្សចោលម្សៀតជាច្រើននាក់។ មនុស្សចោលម្សៀតកម្រិតទាប គ្រប់គ្រងមនុស្សចោលម្សៀតកម្រិតខ្ពស់។ មនុស្សចោលម្សៀតមិនដឹងខ្លួនថាចោលម្សៀតទេ ព្រោះជឿខ្លួនឯងកំពុងធ្វើរឿងដែលមានតម្លៃ ហើយគេហៅការងាររបស់គេថា ភាពជោគជ័យ។

ខ្ញុំជាមនុស្សចោលម្សៀតម្នាក់ ដែលធ្វើការបម្រើមនុស្សជោគជ័យពីរបីនាក់។ ពួកគេមានកំណើត និងមានគំនិតរកស៊ីដោយខ្លួនឯង ហេតុនេះពួកគេក៏ផ្ដល់ឱកាសឱ្យខ្ញុំដើម្បីបានលុយចាយខ្លះ និងបន្តភាពចោលម្សៀតរបស់ខ្ញុំទៀត។ វត្តមានរបស់ខ្ញុំគឺជាជំនួយរបស់គេ។ ខ្ញុំជួយធ្វើការឱ្យគេ ដើម្បីកុំឱ្យគេក្លាយជាមនុស្សចោលម្សៀតដែរ។

យើងបែងចែកមនុស្សជាពីរប្រភេទ គឺមនុស្សជោគជ័យ និងមនុស្សចោលម្សៀត។ បើយើងមិនមែនជាមនុស្សជោគជ័យទេ យើងគឺជាមនុស្សចោលម្សៀត។ ការហៅខ្លួនឯងថា “អ្នកដែលមិនទាន់ជោគជ័យ” ឬ “កំពុងដើរលើផ្លូវជោគជ័យ” គឺជាបោកប្រាស់ខ្លួនឯងប៉ុណ្ណោះ។ ការដែលយើងមិនទាន់ជោគជ័យហ្នឹងហើយ ដែលធ្វើឱ្យយើងក្លាយជាមនុស្សចោលម្សៀត។ ពេលដែលយើងទទួលបានជោគជ័យរួច ឈ្មោះថាចោលម្សៀត ក៏ប្រើលែងត្រូវជាមួយយើងដែរ។ គ្មានការលើកលែង ឬបង្កើតពាក្យថ្មីណា អាចជួយកែប្រែវាសនាមនុស្សចោលម្សៀតបានទេ។

បើសិនជាខ្ញុំនិយាយថា “ខ្ញុំជាអ្នកនិពន្ធដែលមិនទាន់ល្បី” ឬ “ខ្ញុំជាអ្នករកស៊ីដែលមិនទាន់មានលទ្ធភាពបើករបររកស៊ី” តើខ្ញុំជាមនុស្សបែបណា? ចម្លើយមានតែមួយគត់ គឺចោលម្សៀត។ ខ្ញុំចែកដាច់បែបនេះ គឺដើម្បីកុំឱ្យខ្លួនឯងវង្វេង។

ខ្ញុំវង្វេងនឹងជោគជ័យក្លែងក្លាយរបស់ខ្លួនឯងរាប់ឆ្នាំមកហើយ។ ខ្ញុំគិតថា ការបានចូលរួមប្រឡងសិស្សពូកែ ជាជោគជ័យរបស់ខ្ញុំ ទោះបីខ្ញុំមិនបានជាប់លេខនឹងគេក៏ដោយ។ ខ្ញុំនៅលួងខ្លួនឯងទៀតថា ទោះខ្ញុំមិនជាប់ តែខ្ញុំបានទទួលបទពិសោធន៍។ ខ្ញុំទុកការបរាជ័យ ជាជោគជ័យ។ ខ្ញុំមិនយកវាមកធ្វើជាមេរៀន ហើយខ្ញុំក៏មិនដែលបន្ទោសខ្លួនឯងដែរ ព្រោះខ្ញុំស្រលាញ់ខ្លួនឯងខ្លាំងពេក។

អ្នកដែលធ្លាប់អានសៀវភៅរបស់ខ្ញុំពីមុន នឹងឃើញខ្ញុំលើកតម្កើងពីស្នាដៃបន្តិចបន្តួចដូចជា សៀវភៅ អត្ថបទ និងកិច្ចការឪហ្សាញ។ ខ្ញុំគិតថា វាជាភាពជោគជ័យ ហេតុនេះខ្ញុំក៏យកមកបង្ហាញអ្នកដទៃ ដោយមានមោទនភាពលើខ្លួនឯង។

ការពិត គឺនៅនឹងភ្នែក គ្រាន់តែខ្ញុំផ្លាស់ប្តូរវាប៉ុណ្ណោះ។ សៀវភៅរបស់ខ្ញុំ មិនល្បីដូចខ្ញុំគិតនោះទេ។ អត្ថន័យក្នុងសៀវភៅ ក៏មិនល្អដល់ថ្នាក់អាចយកមកអួតគេបានដែរ។ អ្នកអានសៀវភៅរបស់ខ្ញុំ ក៏មានមិនដល់១០០នាក់ផង។ តើខ្ញុំបានអ្វីមកហៅថា នេះជាជោគជ័យ។

កាលពីចុងឆ្នាំ២០១៦ ខ្ញុំបានសរសេរអត្ថបទមួយអំពីអ្វីដែលខ្ញុំបានធ្វើក្នុងរយៈពេលមួយឆ្នាំ។ ខ្ញុំរាប់បញ្ចូលទាំងការរៀនមុខវិជ្ជាលើអ៊ីនធឺណេត ការអានសៀវភៅ និងរឿងកំប៉ិកកំប៉ុកដទៃទៀត។ ខ្ញុំសប្បាយចិត្តនឹងអ្វីដែលខ្ញុំបានធ្វើ។ ខ្ញុំមិនមែនសប្បាយដោយសារតែទំហំ និងចំនួនស្នាដៃរបស់ខ្ញុំទេ តែខ្ញុំសប្បាយដោយសារខ្ញុំបំប៉ោងស្នាដៃទាំងនោះ ដោយបន្ថែមន័យទៅលើវា។ ការងារខ្លះ គ្មានតម្លៃទេ តែខ្ញុំប្រើជំនាញសរសេររបស់ខ្ញុំ ទៅបំភ័ន្តភ្នែកខ្លួនឯង។ អ្នកអានរួច អាចនឹងយល់ថា ខ្ញុំខំប្រឹងប្រែង ឬមានកំណើត តែតាមពិត ខ្ញុំនៅតែចោលម្សៀតដដែល។

ខ្ញុំភ្លេចគិតថា បើសិនជាមនុស្សបោលម្សៀតក្នុងលោកនេះ មានចំនួនច្រើនជាងមនុស្សជោគជ័យ ខ្ញុំក៏អាចជាមនុស្សបោលម្សៀតម្នាក់ដែរ។ ដោយសារតែភ្លេចគិតពីរឿងនេះ ទើបខ្ញុំមិនដែលចាប់អារម្មណ៍សង្កេតមើលរោគសញ្ញាបោលម្សៀតរបស់ខ្លួនឯង។ ខ្ញុំសង្កេតអ្នកដទៃ ព្រោះនេះជាវិធីរៀនពីមនុស្សរបស់ខ្ញុំ តែខ្ញុំមិនសូវមានពេលសង្កេតខ្លួនឯង។ ទម្លាប់បោលម្សៀតបែបនេះ ទើបឱ្យខ្ញុំគិតថា ខ្ញុំយល់ពីមនុស្សកាន់តែច្រើនក្នុងរយៈពេល ២ឆ្នាំចុងក្រោយ តែតាមពិត ខ្ញុំមិនយល់សូម្បីតែខ្លួនឯង។

វត្តមានរបស់មនុស្សបោលម្សៀត ជារឿងល្អសម្រាប់មនុស្សជោគជ័យ។ ពួកគេ ធ្វើឱ្យមនុស្សជោគជ័យលេចធ្លោកាន់តែខ្លាំង ក្នុងកាលៈទេសៈណាមួយ។ ពួកគេ ក៏ជាអ្នកជួយជម្រុញឱ្យមនុស្សជោគជ័យ អាចធ្វើរឿងពិបាកៗបានច្រើនជាងមុនទៀតផង។ ជីវិតរបស់មនុស្សបោលម្សៀត រស់ដើម្បីអ្នកដទៃក្លាយជាមនុស្សជោគជ័យ។ ពួកគេគិតថា ពេលអ្នកដទៃជោគជ័យ ខ្លួនគេក៏បានរួមចំណែកដូចគ្នា។

មនុស្សបោលម្សៀត រស់លាយឡំជាមួយមនុស្សជោគជ័យ ដូច្នេះពួកគេអាចប្រឡំថាខ្លួនឯង ក៏ស្ថិតក្នុងជំពូកមនុស្សជោគជ័យដែរ។ ពួកគេប្រឹងធ្វើតាមគេតែសម្បកក្រៅ ដូចជា រៀនប្រើកាយវិការ រៀននិយាយស្ដី រៀនស្លៀកពាក់ ឬរៀនបង្ហោះពាក្យល្អៗលើអ៊ីនធឺណេត តែពេលមើលទៅខាងក្នុងវិញ គឺប្រហោងធ្លុះ។ មនុស្សបោលម្សៀតជាធុងដែលគ្មានបាត ល្អមើលពីខាងក្រៅ តែប្រើការមិនកើត។ គេហៅថា ធុងដូចគ្នា តែមិនអាចប្រើបាន។

បើសិនជាខ្ញុំជឿលើព្រះ ខ្ញុំអាចនឹងគិតថា ព្រះបង្កើតមនុស្សបោលម្សៀតមក ដើម្បីបម្រើមនុស្សជោគជ័យ ដែលជាសំណព្វចិត្តរបស់ព្រះមិនខាន។ ទោះជឿ ឬមិនជឿ ក៏វានៅតែជាការពិតរបស់មនុស្សបោលម្សៀតដែរ។

# និយមន័យមនុស្សចោលម្សៀត

ខ្ញុំនឹងព្យាយាមកំណត់និយមន័យរបស់មនុស្សចោលម្សៀត ដើម្បីងាយយល់ទាំងអស់គ្នា។ បើតាមនិយមន័យក្នុងវចនានុក្រមសម្តេចជួនណាត ចោលម្សៀត មានន័យថា មិនកើតការ , មិនបានការ , ប្រើការមិនកើត។ វាកើតចេញពាក្យថា ម្សៀត ដែលមានន័យថា ប្រយោជន៍ ឬសេចក្តីកើតការ។ និយមន័យនេះ មិនទាន់គ្រប់គ្រាន់ឱ្យយើងយល់ពីមនុស្សចោលម្សៀតទេ។ យើងអាចយល់ពីន័យពាក្យនេះមែន តែបើចង់យល់ដល់មនុស្សប្រភេទនេះ ត្រូវមើលលើអ្វីដែលគេធ្វើ គិត និងនិយាយស្តី។

## ១ បោះចោលជីវិតខ្លួនឯង

ពីដំបូង ខ្ញុំមិនគិតថា ខ្ញុំបោះចោលជីវិតខ្លួនឯងទេ ព្រោះខ្ញុំគិតថា ខ្ញុំមានការងារធ្វើ និងបានរើសយកអាជីពជាអ្នកនិពន្ធ។ ក្រោយមក ខ្ញុំអានប៉ះនឹងទស្សនវិជ្ជាមួយចំនួនដែលធ្វើឱ្យគិតថា ជីវិត គឺគ្មានន័យ។ មិនថាខ្ញុំប្រឹងធ្វើអ្វីទេ ចុងក្រោយ ខ្ញុំនឹងរលាយបាត់ពីពិភពលោកនេះដដែល។ គ្មានជាតិមុន គ្មានជាតិក្រោយ អ្វីដែលខ្ញុំមានគឺពេលបច្ចុប្បន្ន ហើយជារឿងបណ្តោះអាសន្នទៀត។

ខ្ញុំកាន់តែអាន ខ្ញុំកាន់តែគិតទៅរកផ្លូវនោះ រហូតដល់ពេលខ្លះ ខ្ញុំលែងមានអារម្មណ៍អ្វីទាំងអស់។ ខ្ញុំមានសេរីភាព និងអាចទម្លាក់ចោលទំនួលខុសត្រូវ។ ខ្ញុំរីករាយផង និងវេទនាផង។ អ្វីដែលខ្ញុំវេទនា គឺខ្ញុំមិនអាចបង្កើតអត្ថន័យឱ្យជីវិតខ្លួនឯងបាន។

ខ្ញុំចាប់ផ្តើមផ្អាកសរសេរសៀវភៅ ហើយមិនធ្វើអ្វីទាំងអស់។ ខ្ញុំលែងខ្វល់ពីអ្វីដែលខ្ញុំធ្វើ ហើយរស់នៅតាមទម្លាប់ថ្មីរបស់ខ្ញុំ។ ខ្ញុំទៅធ្វើការពេញម៉ោង ហើយត្រលប់មកវិញដេកមើលរឿងគ្រប់ប្រភេទ។ ខ្ញុំមិនដឹងសរសេរអី ហើយក៏មិនដឹងសរសេរដើម្បីអី។ ខ្ញុំមិនត្រឹមតែគិតថា ជីវិតខ្ញុំគ្មានន័យទេ ខ្ញុំក៏គិតថា ជីវិតអ្នកដទៃគ្មានន័យដូចគ្នា។

ពេលខ្លះខ្ញុំមានរឿងដែលចង់សរសេរ តែត្រូវឈប់វិញ ព្រោះគិតថា តើវាមានន័យអី បើជីវិតអ្នកសរសេរ និងអ្នកអានសុទ្ធតែអត់ន័យ។

មនុស្សបោលម្សៀត មិនឱ្យតម្លៃជីវិតទេ។ ពួកគេ មិនដឹងថា តើអ្វីជាតម្លៃ ក្រោយពេលវែកញែកអស់ចិត្តទៅ។ តម្លៃដែលពួកគេអាចបង្កើតដោយខ្លួនឯង ក៏មិននៅបានយូរដែរ។

# ២ និយាយឱ្យអ្នកដទៃបោះបោលក្ដីស្រមៃដែរ

ទំនាក់ទំនងជាមួយអ្នកដទៃ មិនមែនជា ចំណុចល្អរបស់ខ្ញុំទេ។ ខ្ញុំតែងតែមើលអ្នកដទៃក្នុងផ្លូវអាក្រក់ជានិច្ច ហេតុនេះ ទើបខ្ញុំជៀសវាងនិយាយជាមួយពួកគេ។ ខ្ញុំគិតថា បើខ្ញុំមិននិយាយជាមួយគេ គេក៏មិនអាចកុហកខ្ញុំ ហើយខ្ញុំក៏មិនចាំបាច់ធ្វើពុតអ្វីទាំងអស់។

មនុស្សបោលម្សៀតទូទៅ ធ្វើបែបនេះ។ ពេលឃើញអ្នកណាម្នាក់កំពុងប្រឹងធ្វើអ្វីមួយ គេនឹងមកនិយាយពាក្យបំបាក់ទឹកចិត្ត ឬមើលងាយការប្រឹងប្រែងរបស់គេ។ សូម្បីតែគេធ្វើបានជោគជ័យហើយក៏ដោយ ក៏មនុស្សបោលម្សៀតមិនលើកលែងឱ្យដែរ។

មនុស្សបោលម្សៀត គិតថាបើខ្លួនមិនបានធ្វើ អ្នកដទៃ ក៏មិនចាំបាច់ធ្វើដែរ។ ត្រូវប្រយ័ត្នមនុស្សបោលម្សៀតដែលសម្បូរទ្រឹស្ដី ដូចជាខ្ញុំ។ ពេលខ្លះ គេអាចប្រើអ្វីដែលគេដឹង មកនាំចិត្តអ្នកដទៃឱ្យបោះបង់បោលគ្រប់យ៉ាង ហើយរស់នៅតាមយថាកម្ម។

ខ្ញុំអាចលើកជាឧទាហរណ៍បាន ចំពោះចំណុចនេះ។ មនុស្សក្នុងសាសនា ភាគច្រើនមានជំនឿទៅលើការថែរក្សា និងជួយទំនុកបម្រុងពីកម្លាំងក្រៅខ្លួន។ វាអាចជា ព្រះទេវតា ឬព្រលឹងដូនតា។ ដោយសារគេជឿ ទើបគេអាង។ ពេលមានអាង ក៏ប្រើការអាងនោះ មកបង្វិលការគិតរបស់ខ្លួន កុំឱ្យខ្វល់ពីអ្វីទាំងអស់។ គេគិតថា គេរស់នៅ

ដោយមានក្តីសុខ។ គេក៏ចង់ឱ្យអ្នកដទៃទៀត រស់នៅបានដូចគេដែរ ហេតុនេះ គេក៏ប្រាប់ពីជំនឿរបស់គេ។

មនុស្សដែលមានជំនឿសាសនា ច្រើនណាស់ ជាមនុស្សចោលម្សៀត។ មនុស្សគ្មានសាសនា ក៏ចោលម្សៀតមិនតិចគ្នាដែរ។ បើចោលម្សៀតដូចគ្នាបែបនេះ តើយើងម៉េចនឹងដឹងថា អ្នកណាល្អជាងអ្នកណាទៅ?

## ៣ ច្រណែនលើរឿងមិនសមនឹងច្រណែន

មនុស្សចោលម្សៀត យកការច្រណែនមកធ្វើជាអ្នកនាំផ្លូវ។ ពេលឃើញអ្នកណាម្នាក់អាចធ្វើបាន គេនឹងរកពាក្យយ៉ាងណា មកបង្អាប់អ្វីដែលអ្នកដទៃធ្វើបាន ដើម្បីកុំឲ្យខ្លួនឯងមានអារម្មណ៍ថាអន់ជាងគេ។

ពួកគេ បានត្រឹមតែច្រណែនប៉ុណ្ណោះ តែគ្មានបំណងថាធ្វើសកម្មភាពអ្វី ដើម្បីបានដូចគេទេ។ គម្រោងរបស់ពួកគេ គឺយកអារម្មណ៍ច្រណែនមកប្រើមួយភ្លែត រួចហើយក៏បន្តជីវភាពចោលម្សៀតទៀត។

ខ្ញុំច្រណែននឹងអ្នកដែលមានឱកាសការងារច្រើនជាងខ្ញុំ។ ខ្ញុំច្រណែនគេដែលអាចប្តូរការងារបានតាមចិត្ត ហើយមិនបាច់រង់ចាំ។ ខ្ញុំច្រណែនគេ តែខ្ញុំមិនដែលរវល់ទៅ កែ CV ថ្មីអ្វីទេ ហើយក៏មិនដែលប្រឹងស្វែងរកការងារថ្មីអ្វីដែរ។ ខ្ញុំច្រណែនអ្វីដែលខ្ញុំមិនបានធ្វើ។

ការច្រណែនរបស់ខ្ញុំ មិនបានជួយអ្វីទាំងអស់ ក្រៅពីធ្វើឱ្យមិនពេញចិត្តនឹងអ្នកដទៃ។ រឿងដែលមិនសមនឹងច្រណែន គឺរឿងដែលខ្ញុំមិនហ៊ានធ្វើ និងមិនប្រឹងធ្វើ។ មនុស្សចោលម្សៀត ខាតពេលជាមួយការច្រណែន និងសង្ឃឹមថាគ្រប់យ៉ាងដែលគេចង់បាន នឹងរត់មករកគេនៅថ្ងៃណាមួយ។

# ៥ ធ្វើអ្វីមិនបានសម្រេច ហើយពូកែតែមាត់

លទ្ធផល ជាការបញ្ជាក់ថា អ្នកណាជាមនុស្សចោលម្សៀត ឬជោគជ័យ។ មនុស្សចោលម្សៀត បានតែមាត់ប៉ុណ្ណោះ អ្វីក៏ធ្វើមិនចេញដែរ។ ពួកគេយល់ថា ការនិយាយចោល ជាជោគជ័យ។ ឱ្យតែបាននិយាយពីគម្រោងដែលគេចង់ធ្វើ គេក៏មានអារម្មណ៍ល្អ ដូចធ្វើរឿងនោះបានជោគជ័យដែរ។

នៅពេលគេនិយាយអស់ចិត្ត ហើយធ្វើអ្វីមិនចេញ គេនឹងប្តូរទៅគិតពីរឿងផ្សេងទៀត ហើយបន្តសកម្មភាពដដែលដូចដើម។ ភាពជោគជ័យ មានតែក្នុងក្តីស្រមៃរបស់ពួកគេប៉ុណ្ណោះ គ្មានរូបពិតប្រាកដទេ។

មនុស្សចោលម្សៀត ពូកែសន្យា និងបំប៉ោងសមត្ថភាពរបស់ខ្លួន។ ពួកគេ គិតថា ការធ្វើខុសអ្វីដែលខ្លួននិយាយ ជារឿងធម្មតា ហើយអ្នកណាក៏ធ្វើខុសបែបនេះដែរ។ នេះជាការពិត ព្រោះមនុស្សជាច្រើន ជាមនុស្សចោលម្សៀត។

នៅពេលសន្យាអ្វីមួយ យើងមិនមែនសន្យាតែជាមួយអ្នកដទៃទេ យើងក៏សន្យាជាមួយខ្លួនឯងដែរ។ បើយើងធ្វើមិនបានដូចអ្វីដែលយើងនិយាយ តើសម្តីរបស់យើងមានន័យអ្វីទៀតសម្រាប់ខ្លួនឯង? មិនបាច់គិតដល់អ្នកដទៃទេ ព្រោះគេច្បាស់ជាអស់ទំនុកចិត្តលើយើងរួចហើយ។

ខ្ញុំធ្វើរឿងមិនសម្រេចច្រើនណាស់។ ខ្ញុំមានបំណងទិញសៀវភៅមួយទឹក មកលក់បន្តតែខ្ញុំធ្វើមិនបាន១ខែផង ខ្ញុំក៏ឈប់បាត់។ ខ្ញុំយកសៀវភៅទៅដាក់តាំងក្នុងទូសៀវភៅខ្ញុំ ហើយប្រាប់ខ្លួនឯងថា "យ៉ាងហោចណាស់ ក៏ខ្ញុំអាចយកសៀវភៅនោះមកអានដែរ"។ ការមានសៀវភៅអាន មិនមែនជារឿងអាក្រក់ទេ តែខ្ញុំមិនធ្វើតាមអ្វីដែលខ្ញុំគ្រោងទុក ទើបជារឿងបរាជ័យ។ បរាជ័យ បង្រៀនមនុស្សឱ្យដឹងថាខ្លួនឯងនៅតែជាមនុស្សចោលម្សៀត។ បរាជ័យ ក៏បង្រៀនមនុស្សឱ្យចេះលួងខ្លួនឯង ដែលនេះជាការបង្រៀនមនុស្សឱ្យកាន់តែចោលម្សៀតមួយកម្រិតទៀត។

ខ្ញុំមានសៀវភៅច្រើនក្បាលណាស់ ដែលសរសេរមិនចេញ។ សៀវភៅខ្លះ មានតែមាតិកា។ ខ្លះទៀត មានប្រហែល១០សន្លឹក។ ខ្ញុំមិនសរសេរ ព្រោះខ្ញុំសរសេរមិនចេញ និងខ្ជិល។ ពេលខ្ញុំមានគំនិតសម្រាប់សៀវភៅថ្មី ខ្ញុំត្រេកអរណាស់។ ខ្ញុំក៏ប្រកាសឱ្យអ្នកដទៃដឹងនៅលើអ៊ីនធឺណេតភ្លាម តែក្រោយមកខ្ញុំសរសេរមិនចេញ ខ្ញុំក៏បោះវាចោល តែខ្ញុំមិនប្រាប់អ្នកណាទេ។

មនុស្សចោលម្សៀត និយាយតែពីរឿងល្អប៉ុណ្ណោះ សម្រាប់រឿងអាក្រក់ គឺប្រឹងលាក់ទុក។ សៀវភៅដែលខ្ញុំគ្រោងនឹងសរសេរ សុទ្ធតែជាសៀវភៅដែលទាក់ទងនឹងសៀវភៅចាស់ៗរបស់ខ្ញុំ។ វាជាឱកាសដែលខ្ញុំអាចលក់សៀវភៅជាឈុតបាន។ ខ្ញុំដឹងហើយ តែខ្ញុំមិនធ្វើ។ ខ្ញុំធ្វើរឿងអត់ប្រយោជន៍ ជំនួសឱ្យកិច្ចការដែលអាចជួយឱ្យខ្ញុំលក់សៀវភៅបានច្រើនជាងមុន។

រឿងដែលខ្ញុំធ្វើមិនកើតច្រើនណាស់ ហើយខ្ញុំទើបនឹងភ្ញាក់ខ្លួនប៉ុណ្ណោះ។ ខ្ញុំបោះចោលថ្នាក់ហ្គីតា។ ខ្ញុំឈប់ទៅហាត់ក្បាច់គុន។ ខ្ញុំឈប់រៀនកាត់តវីដេអូ។ ខ្ញុំឈប់រៀនសរសេរ script រឿង។ ខ្ញុំឈប់រៀនសរសេរកូដទូរស័ព្ទដៃ។ ខ្ញុំមិនអាចសន្សំលុយបាន។ ខ្ញុំមិនអាចរកការងារដែលមានប្រាក់ខែខ្ពស់ជាងពេលនេះបាន។ ខ្ញុំគ្មានសមត្ថភាពទិញឡានជិះ។ ខ្ញុំមិនអាចបោះពុម្ពសៀវភៅដោយខ្លួនឯងបាន។

ខ្ញុំបានតែមាត់ប៉ុណ្ណោះ។ អ្វីដែលបានធ្វើ និងអ្វីដែលខ្ញុំគ្រោងនឹងធ្វើ មានចំនួនខុសគ្នាឆ្ងាយណាស់។

# ៥ បម្រើអ្នកដទៃ

សម្រាប់ខ្ញុំ បើការងារដែលយើងធ្វើ មិនហុចប្រយោជន៍ពាក់កណ្ដាល ឬទាំងស្រុងត្រលប់មកយើងវិញទេ ការងារនោះមិនមែនជារបស់យើងទេ។ បើយើងចំណាយពេលធ្វើការងារឱ្យអ្នកដទៃ យើងជាមនុស្សចោលម្សៀតហើយ។ ពេលវេលា ជារបស់មានតម្លៃជាងគេរបស់មនុស្ស។ បើយើងប្រើវាដើម្បីបំពេញបំណងអ្នកដទៃ បានន័យ

ថា របស់មានតម្លៃរបស់យើង ក្លាយជាឈ្នាន់ដើម្បីឱ្យគេឡើងទៅលើ។ តើយើងមានពេលប៉ុន្មានឆ្នាំ ដើម្បីឱ្យគេជាន់រាល់ថ្ងៃ?

ខ្ញុំមានមោទនភាពនឹងការប្ដូរការងាររបស់ខ្ញុំ។ ខ្ញុំតែងតែយកវាមកសរសេររហូត ដើម្បីឱ្យអ្នកដទៃដឹងថា ការប្ដូរការងារ ជារឿងសប្បាយ។ ឥលូវនេះ វាលែងមានអីដែលត្រូវសប្បាយទៀតហើយ ព្រោះទោះបីជាខ្ញុំប្ដូរទៅធ្វើការកន្លែងណា ខ្ញុំនៅតែជាមនុស្សចោលម្សៀតដដែល។

ខ្ញុំបម្រើមហិច្ឆតាអ្នកដទៃ ព្រោះខ្ញុំគ្មានកំណើតធ្វើការឱ្យខ្លួនឯង។ ខ្ញុំធ្វើជាខ្ញុំគេ ព្រោះខ្ញុំមិនហ៊ានប្រថុយ។ ខ្ញុំរស់នៅដោយសារលុយដែលគេចែកឱ្យ ព្រោះខ្ញុំគ្មានសមត្ថភាពរកលុយដោយការងារខ្លួនឯង។ ខ្ញុំជាមនុស្សចោលម្សៀត ដែលពឹងលើខួរក្បាលរបស់គេ ដើម្បីរស់។

យើងអាចប្រកែកយ៉ាងម៉េចក៏បានដែរ ព្រោះភាពចោលម្សៀត មិនបាត់ទៅវិញដោយសារយើងពូកែប្រកែកទេ។ យើងធ្វើការឱ្យគេ យើងជាមនុស្សគ្មានកំណើត។ ខ្លី និងងាយយល់ជាទីបំផុត។ ឥលូវនេះ ខ្ញុំយល់ន័យដែលមីងខ្ញុំសួរខ្ញុំពីមុនហើយ “ខំរៀនធ្វើអី បើគង់តែធ្វើការឱ្យដដែល”។

មនុស្សចោលម្សៀត រស់ក្រោមដំបូលនៃភាពជោគជ័យរបស់អ្នកដទៃ។ ជីវិតរបស់ពួកគេពោរពេញទៅអត្ថន័យក្លែងក្លាយ ដែលបង្កប់ដោយការមើលងាយខ្លួនឯង និងការសើចចំអកពីអ្នកដទៃ។ មនុស្សចោលម្សៀត គិតថាខ្លួនអាចរកភាពជោគជ័យឃើញ នៅក្នុងកន្លែងរបស់អ្នកដទៃ។

ប្រាក់ខែ ឋានៈ មុខមាត់បន្តិចបន្តួច រង្វាន់លើកទឹកចិត្ត និងពាក្យសរសើរដែលមិនច្បាស់លាស់ ជារបស់គ្រប់គ្រងមនុស្សចោលម្សៀត។ ទាំងនេះ ជានិយមន័យនៃភាពជោគជ័យដែលខ្ញុំមានក្នុងខួរក្បាល។ តាមពិត ខ្ញុំមិនមានវាទេ តែខ្ញុំប្រឹងញាត់វាចូលឱ្យពេញក្នុងខួរក្បាលខ្ញុំ ដើម្បីក្លាយជាមនុស្សចោលម្សៀតដ៏ជោគជ័យម្នាក់។

# សរុប

និយមន័យទាំងនេះ ជាការយល់ឃើញរបស់ខ្ញុំក្នុងដំណាក់កាលទើបនឹងភ្ញាក់ខ្លួន។ វាអាចមានចំណុចខ្វះខាតច្រើន តែដូចខ្ញុំប្រាប់មុនហើយ ពេលនេះខ្ញុំជាមនុស្សចោលម្សៀត អ្វីដែលខ្ញុំធ្វើ មិនអាចល្អគ្រប់ជ្រុងទេ។ ខ្ញុំកំពុងរកផ្លូវចេញ តាមរយៈការសរសេរចេញមកឱ្យអស់។

មនុស្សចោលម្សៀត ជាមនុស្សដែល៖

១ បោះបោលជីវិតខ្លួនឯង
២ និយាយឱ្យអ្នកដទៃបោះបោលក្តីស្រមៃដែរ
៣ ច្រណែនលើរឿងមិនសមនឹងច្រណែន
៤ ធ្វើអ្វីមិនបានសម្រេច ហើយពូកែតែមាត់
៥ បម្រើអ្នកដទៃ

# ប្រភេទនៃមនុស្សចោលម្សៀត

ការរស់នៅរបស់យើងមានច្រើនផ្នែក ហេតុនេះផ្នែកដែលយើងជាមនុស្សចោលម្សៀត ក៏បែងចែកទៅតាមនោះដែរ។ ខ្ញុំចែកមនុស្សចោលម្សៀតទៅតាមប្រភេទផ្សេងគ្នាដើម្បីខ្ញុំងាយស្រួលវិភាគខ្លួនឯងថា នៅក្នុងប្រភេទណាខ្លះ។ យើងអាចស្ថិតក្នុងប្រភេទមួយ ឬច្រើន។ បើមានកាន់តែច្រើន យើងកាន់តែចោលម្សៀត។

ខ្ញុំចែកជា ៥ប្រភេទ គឺ

១ ការអប់រំ និងចំនេះដឹង
២ ហិរញ្ញវត្ថុ
៣ អាជីព
៤ គ្រួសារ និងស្នេហា
៥ សុខភាព

## ១ ការអប់រំ និងចំនេះដឹង

យើងមិនអាចរស់នៅដោយគ្មានចំណេះដឹងបានទេ។ បើយើងរៀនបានច្រើន និងត្រូវកន្លែង យើងអាចនឹងរកផ្លូវទទួលបានជោគជ័យខ្លះ។ ឧទាហរណ៍ មិត្តភក្តិរបស់ខ្ញុំ ជាកូនចៅកែលក់ពេជ្រ ដូច្នេះ គេទៅរៀនពីវិធីច្នៃម៉ូតគ្រឿងពេជ្រ និងវិធីលក់។ គេមានចំណេះដឹងផ្នែកនេះកាន់តែច្រើន ភាពជោគជ័យរបស់គេក៏កាន់តែខ្ពស់។

ការអប់រំ មិនចាំបាច់ទាល់តែធ្វើនៅក្នុងសាលាទេ ព្រោះឥលូវយើងមានអ៊ីនធឺណេត។ ឯកសារច្រើនណាស់ ត្រូវបានគេដាក់នៅលើអ៊ីនធឺណេត ដើម្បីឱ្យអ្នកដែលគ្មានឱកាស បានស្វែងយល់ដោយខ្លួនឯង។ កម្រិតនៃការយល់ដឹង គឺត្រូវពឹងលើខ្លួនយើង។ យើងប្រឹង យើងបាន យើងចាំគេមកបង្រៀន យើងអត់។

មនុស្សចោលម្សៀតក្នុងផ្នែកចំណេះដឹង ជាមនុស្សល្ងង់ ហើយមិនចង់ចេះ។ ពួកគេមិនចូលចិត្តរៀនអ្វីថ្មី ហើយតែងតែគិតថា ខ្លួនឯងមានចំណេះដឹងគ្រប់គ្រាន់ជានិច្ច។ អ្វីដែលគេមាន គឺការបោកខ្លួនឯងប៉ុណ្ណោះ។

មនុស្សចោលម្សៀតប្រភេទនេះ ច្រើនតែនិយាយចេញមកមិនដឹងក្បាលកន្ទុយ ហើយពូកែតែខាងឈ្លោះ។ ពួកគេឈ្លោះដើម្បីរក្សាភាពល្ងង់ខ្លៅឱ្យនៅគង់វង្ស។ ពួកគេក៏អាចឈ្លោះដោយសារការយល់ច្រឡំដែរ។ ពួកគេពូកែច្រឡំណាស់ ព្រោះគេគ្មានចំណេះដឹងពិតប្រាកដ។

មនុស្សចោលម្សៀតប្រភេទនេះ មានច្រើនក្នុងសង្គមខ្មែរ។ ពួកគេមានអ៊ីនធឺណេត តែមិនឆ្លៀតរៀនដោយខ្លួនឯង។ ពួកគេប្រើលេសថា គ្មានលទ្ធភាពទៅសាលាដូចគេ តែពួកគេមិនប្រើអ្វីដែលគេមានស្រាប់ក្នុងដៃទេ។ មានអ៊ីនធឺណេត តែមិនចេះប្រើ ជារឿងចោលម្សៀតបំផុតក្នុងសម័យតិចណូឡូជី។

ខ្ញុំមិនស្ថិតក្នុងប្រភេទនេះទេ ព្រោះខ្ញុំរៀនអ្វីថ្មីរាល់ថ្ងៃ។ ខ្ញុំរៀនដោយខ្លួនឯងផង និងត្រូវគេបង្ខំឱ្យរៀននៅកន្លែងធ្វើការផង។ យើងដឹងហើយថា មនុស្សចោលម្សៀតជៀសមិនផុតពីត្រូវគេបង្ខំឱ្យកិច្ចការដែលខ្លួនមិនចង់ធ្វើនោះទេ។

ខ្ញុំមានអ៊ីនធឺណេតនៅផ្ទះ ដូច្នេះក្រៅពីមើលកីឡាកាស ស្តាប់ចម្រៀង និងមើលរឿងអាសអាភាស ខ្ញុំនៅរៀនតាមអនឡាញ អានឯកសារស្រាវជ្រាវក្នុងផ្នែកវិទ្យាសាស្ត្រ និងអានពត៌មានសំខាន់ៗ។ ខ្ញុំប្រើអ៊ីនធឺណេតអស់ថ្លៃ ទាំងមានប្រយោជន៍ និងអត់ប្រយោជន៍។ ខ្ញុំគ្មានលុយទៅរៀនដល់ស្រុកក្រៅមែន តែខ្ញុំអាចរកមេរៀនដែលគេបង្រៀននៅស្រុកក្រៅមករៀនបាន។ ខ្ញុំអាចមិនចេះ១០០ភាគរយ តែវាគ្រាន់បើជាងអត់ចេះអ្វីសោះ។

# ២ ហិរញ្ញវត្ថុ

ទោះបីខ្ញុំចោលម្សៀតមែន តែខ្ញុំដឹង និងទទួលស្គាល់ថា លុយជារបស់មាន ប្រយោជន៍។ យើងអាចប្រើលុយទៅធ្វើរឿងដែលមិនអាចនឹកស្មានដល់។ នេះជា ចំណុចចោលម្សៀតរបស់ខ្ញុំ។ ខ្ញុំអាយុ២០ឆ្នាំជាង តែគ្មានលុយសន្សំ និងគ្មាន ចំណូលច្រើនផ្លូវ។

សង្សារខ្ញុំធ្លាប់សួរខ្ញុំថា “បើរៀបការហើយ ប្រាក់ខែប៉ុណ្ណឹង ធ្វើម៉េចអាចចិញ្ចឹមខ្លួនឯង រស់”។ សង្សារខ្ញុំអាចនឹងគិតពីលុយច្រើនជាងខ្ញុំ ប៉ុន្តែនេះបញ្ជាក់ថា ខ្ញុំនៅស្ទើរភ្លើង។ យើងមិនអាចរស់ស្រួលដោយគ្មានលុយទេ។ លុយបន្តជីវិតមនុស្ស។ បើខ្ញុំមិនគិតពី វា ខ្ញុំក៏មិនចង់បានវា។ បើខ្ញុំមិនចង់បាន ខ្ញុំក៏មិនរកវិធីរកលុយឱ្យបានច្រើនដែរ។ បើខ្ញុំ គ្មានលុយច្រើន ថ្ងៃណាមួយដែលជួបបញ្ហា ខ្ញុំនឹងត្រូវបន្ទោសអ្នកដទៃថាមិនព្រម ជួយខ្ញុំមិនខាន។

លុយ ជាខ្នងបង្អែកដ៏សំខាន់។ មនុស្សចោលម្សៀត ដឹងពីរឿងនេះ តែពួកគេយក សម្ដីអ្នកប្រាជ្ញជំនាន់មុនមកប្រើ ដោយថា “ការគិតពីលុយ ជាប្រភពនៃអំពើ អាក្រក់”។ ការគិតបែបនេះឡូយណាស់ តែវាគ្មានប្រយោជន៍។ ការគិតពីលុយ អាច ជាប្រភពនៃអំពើអាក្រក់ តែការធ្វើជាមនុស្សចោលម្សៀត ជាអំពើអាក្រក់តែម្ដង។

ខ្ញុំកើតក្នុងគ្រួសារក្រ ហេតុនេះខ្ញុំដឹងច្បាស់ណាស់ថា បើអត់លុយ ជីវិតយើងនឹងទៅ ជាយ៉ាងណា។ ខ្ញុំដឹងហើយ តែបែរជាមិនខ្វល់ពីលុយទៅវិញ។ ត្រង់នេះដែលបញ្ជាក់ ថា ខ្ញុំចោលម្សៀតពេញទំហឹងតែម្ដង។

ខ្ញុំធ្លាប់អានរឿង និងមើលបទចម្រៀងដែលគេរៀបរាប់ពីទុក្ខលំបាករបស់អ្នកក្រ។ ពេលខ្លះ ត្រូវព្រាត់គ្នាជាមួយប្រពន្ធ ពេលខ្លះប្រពន្ធរត់ចោល ពេលខ្លះសមាជិកក្នុង គ្រួសារស្លាប់ ដោយសារគ្មានលុយយកទៅឱ្យពេទ្យ។ បើយើងគិតមិនដល់ យើងនឹង បន្ទោសអ្នកដទៃ តែបើយើងគិតឱ្យដល់យើងនឹងបន្ទោសខ្លួនឯង។

យើងអាចបន្ទោសគេថា “យកលុយមកបំបែកគ្រួសារយើង” តែយើងក៏អាចបន្ទោសខ្លួនឯងវិញថា “ដោយសារយើងមិនអាចរកលុយបាន ទើបគ្រួសារយើងបែកបាក់”។ យើងអាចបន្ទោសប្រពន្ធថា “មានចិត្តមិនស្មោះ ផិតក្បត់” តែយើងក៏អាចបន្ទោសខ្លួនឯងថា “យើងគ្មានសមត្ថភាពរកលុយ មិនអាចឱ្យប្រពន្ធរស់នៅសុខបាន”។ យើងអាចបន្ទោសថា “ពេទ្យគ្មានចិត្តធម៌” ឬក៏អាចបន្ទោសខ្លួនឯងថា “យើងល្ងង់មិនត្រៀមលុយសម្រាប់ឈឺ”។

មនុស្សចោលម្សៀតក្នុងរឿងលុយ ចូលចិត្តបន្ទោសអ្នកដែលមានលុយ។ ការបន្ទោសអ្នកដទៃ ជាចរិតកំសាករបស់យើងដែលមិនហ៊ានទទួលស្គាល់ខ្លួនឯង។ បើយើងជាមនុស្សចោលម្សៀត កំហុសគ្រប់យ៉ាង គឺចេញពីយើង។ បើជ្រុលជាលើកឡើងពីបញ្ហា ត្រូវជីកឱ្យដល់ឫសគល់វា។

ខ្ញុំដឹងពីឫសគល់នៃបញ្ហាអត់លុយរបស់ខ្ញុំហើយ គឺខ្ញុំជាមនុស្សចោលម្សៀត។

# ៣ អាជីព

ការងារ និងអាជីព ជារឿងពីរខុសគ្នា។ បើសិនជាយើងមានការងារ នោះបានន័យថាយើងត្រូវបង្ខំចិត្ត ឬអាចមិនបង្ខំទៅធ្វើអ្វីមួយ ដែលជាបញ្ជារបស់ថ្នាក់លើ។ យើងមានការងារ យើងមានតួនាទី ហើយយើងបានចំណូល ឬឋានៈពីវា។ ចំណែកអាជីពវិញ គឺធ្វើដើម្បីខ្លួនយើង។ វាអាចជាការស្រលាញ់ ឬជាទេពកោសល្យពីកំណើត។ អាជីព អាចមិនអាចរកចំណូលឱ្យបានគ្រប់គ្រាន់ទេ បើសិនជាយើងមិនទាន់មានឱកាស ឬអ្នកដទៃមិនផ្ដល់ឱកាសឱ្យ។

មនុស្សភាគច្រើន មិនសូវមានអាជីពទេ ព្រោះវាពិបាក ហើយត្រូវរវល់ដកខ្លួនមិនរួច។ ចំណុចល្អមួយរបស់អាជីព គឺធ្វើឱ្យមនុស្សពេញចិត្តនឹងអ្វីដែលខ្លួនឯងធ្វើ ហើយចង់ធ្វើវាឱ្យបានល្អជាងមុនជានិច្ច។ អាជីព ជាកម្លាំងជម្រុញឱ្យមនុស្សប្រឹងប្រែងធ្វើទៀតផង។ តើអ្នកណាមិនចង់ធ្វើការដើម្បីខ្លួនឯងនោះ?

ខ្ញុំមានការងារមួយ ហើយក៏មានអាជីពមួយដែរ។ ការងាររបស់ខ្ញុំមិនសូវជាប់លាប់ទេ ព្រោះខ្ញុំតែងតែប្តូរចិត្តជានិច្ច។ សព្វថ្ងៃនេះ ការងាររបស់ខ្ញុំ គឺទាក់ទងនឹងការរៀនតាមអនឡាញ។ ខ្ញុំចូលចិត្តការងារនេះ ព្រោះវាអាចឱ្យខ្ញុំមានពេលអានបានច្រើន។ ខ្ញុំគ្មានជោគជ័យក្នុងការងារនេះទេ។ ខ្ញុំអាចធ្វើបានត្រឹមតែយកប្រាក់ខែមកចាយប៉ុណ្ណោះ។ បើចង់ឱ្យល្អបំផុត ក៏ខ្ញុំមិនដឹងធ្វើតាមណាដែរ។ កម្រិតដែលខ្ញុំចេះ មិនខ្ពស់ហួសពីបទពិសោធន៍របស់ខ្ញុំទេ។ នៅក្នុងការងារ ខ្ញុំជាមនុស្សចោលម្សៀតប៉ុណ្ណោះ។

យើងត្រលប់មកមើលអាជីពវិញ។ អាជីពរបស់ខ្ញុំ គឺសរសេរសៀវភៅ។ មិនថាខ្ញុំប្តូរការងារប៉ុន្មានដងទេ ខ្ញុំនៅតែសរសេរសៀវភៅដូចមុនដដែល។ ខ្ញុំប្រហែលជាអាចផ្លាស់ប្តូរប្រធានបទសម្រាប់សរសេរ តែកិច្ចការនៅដដែល។ អាជីពនេះ អាចនឹងស្ថិតស្ថេរបានយូរឆ្នាំ បើសិនជាខ្ញុំនៅតែមានសមត្ថភាពសរសេរបាន។

ខ្ញុំសាកល្បងសរសេរក្នុងឆ្នាំ ២០១៤ ហើយសម្រេចចិត្តថា នឹងប្រឹងសាងឈ្មោះឱ្យខ្លួនឯង ជាអ្នកនិពន្ធល្បីម្នាក់។ មកដល់ឥលូវ គឺជិត៤ឆ្នាំហើយ។ គ្មានអ្នកណាស្គាល់ខ្ញុំ គ្មានអ្នកទិញសៀវភៅខ្ញុំ ហើយក៏គ្មានអ្នករំលឹកពីឈ្មោះខ្ញុំដែរ។

ខ្ញុំអាចកុហកខ្លួនឯងថា មកពីស្រុកខ្មែរ មិនសម្បូរអ្នកអាន ហើយមកពីគេមិនឱ្យតម្លៃអ្នកនិពន្ធ។ បើយើងរុញកំហុសទាំងអស់ទៅឱ្យអ្នកដទៃ យើងនឹងបានធូរចិត្តហើយ ប៉ុន្តែក្រៅពីធូរចិត្ត តើយើងបានអ្វីទៀតទេ? ចុះអាជីពរបស់ខ្ញុំ នឹងទៅជាយ៉ាងណា? ខ្ញុំជាអ្នកនិពន្ធចោលម្សៀតម្នាក់ ហើយព្យាយាមសរសេរ ដោយមិនដឹងថាធ្វើយ៉ាងណាឱ្យឈ្មោះរបស់ខ្ញុំ មានគេទទួលស្គាល់ច្រើន។

ខ្ញុំធ្លាប់និយាយលួងខ្លួនឯងថា “ឱ្យតែមានអ្នកអានសៀវភៅខ្ញុំ១០០នាក់ ខ្ញុំទទួលបានភាពជោគជ័យក្នុងអាជីពជាអ្នកនិពន្ធហើយ”។ គ្មានអ្នកណាធ្វើបែបនេះទេ។ ១០០នាក់ មិនអាចជួយខ្ញុំឱ្យសាងឈ្មោះក្នុងជំនាន់នេះបានទេ។

រឿងតែមួយគត់ដែលខ្ញុំខ្មាសខ្លួនឯង គឺខ្ញុំធ្លាប់អួតប្រាប់សង្សារខ្ញុំ ពីសៀវភៅរបស់ខ្ញុំ។ ខ្ញុំថា សៀវភៅល្អត្រង់នេះ ឡូយត្រង់នោះ ហើយមានគេសរសើរទៀតផង។ ក្រោយមក ប្រហែលជាសង្សារខ្ញុំមើលឃើញថា សៀវភៅរបស់ខ្ញុំមិនល្អដូចអ្វីដែលខ្ញុំនិយាយ គេក៏លែងចាប់អារម្មណ៍ពីសៀវភៅក្រោយៗរបស់ខ្ញុំទៀត។ ខ្ញុំក៏ចាប់អារម្មណ៍ដឹងដែរ ហើយខ្ញុំក៏លែងរំលឹកពីរឿងសៀវភៅរបស់ខ្ញុំជាមួយគេទៀត។

តាមពិត ខ្ញុំមិនរំលឹក មិនមែនមកពីខ្ញុំខ្លាចឈ្លោះគ្នាទេ តែគឺខ្ញុំខ្លាចភាពចោលម្សៀតរបស់ខ្លួនឯង។ ខ្ញុំមិនហ៊ានទទួលស្គាល់ថា ខ្លួនឯងចោលម្សៀត ដែលមិនអាចចាប់អាជីពមួយឱ្យនឹងនរបាន។ ខ្ញុំធ្វើជាមិនខ្វល់ រហូតដល់ពេលមួយដែលខ្ញុំត្រូវតែខ្វល់។ ពេលនោះ គឺឥលូវនេះ។

តើមានអ្វីអន់ជាងមនុស្សប្រុសម្នាក់ ដែលចំណាយពេលវេលាប្រចាំថ្ងៃរបស់ខ្លួន ទៅធ្វើការឱ្យអ្នកដទៃ ដើម្បីឱ្យគេមានភាពជោគជ័យនោះ? តើមានអ្វីអន់ជាងមនុស្សប្រុស ដែលមិនអាចធ្វើជាម្ចាស់ការលើខ្លួនឯងពេញមួយថ្ងៃបាន?

ខ្ញុំធ្វើការពេញម៉ោង ពីព្រឹកដល់ល្ងាច ហេតុនេះគ្មានពេលសរសេរសៀវភៅ។ ដោយសារមកពីធ្វើការអស់កម្លាំង អ្វីក៏ខ្ញុំមិនចង់ធ្វើដែរ។ ខ្ញុំគ្រាន់តែចង់ដេក ហើយព្រឹកឡើងបន្តការងារប្រចាំដែលរបស់ខ្ញុំទៀតប៉ុណ្ណោះ។ ខ្ញុំមិនអាចសរសេរសៀវភៅ ខ្ញុំក៏មិនអាចធ្វើអ្វីដើម្បីអាជីពខ្លួនឯង ហើយត្រូវបន្តជីវិតជាខ្ញុំគេរហូត ព្រោះគ្មានដំណោះស្រាយផ្សេង។

ខ្ញុំធ្លាប់សង្ឃឹមថា អាជីពសរសេរសៀវភៅ នឹងអាចជួយខ្ញុំឱ្យមានប្រាក់ចំណូលជាប្រចាំ ហើយខ្ញុំមិនចាំបាច់ទៅធ្វើការទៀតទេ។

# ៤ គ្រួសារ និងស្នេហា

តើមនុស្សអាចរស់នៅបានយ៉ាងដូចម្ដេច បើគ្មានទំនាក់ទំនង? ទំនាក់ទំនង ធ្វើឱ្យការរស់នៅដែលគ្មានន័យរបស់យើង ប្រែជាមានន័យ។ យើងអាចធ្វើការម្នាក់ឯងក្នុងបន្ទប់បាន ប៉ុន្តែបរិយាកាសការងារនឹងផ្លាស់ប្ដូរ នៅពេលមានមនុស្សត្រឹមតែពីរ ឬបីនាក់ចូលមកអង្គុយធ្វើការជាមួយយើង។

ទំនាក់ទំនងខ្លះ ទាមទារឱ្យយើងរកវិធីបង្កើតវា តែទំនាក់ទំនងខ្លះទៀត គឺយើងទទួលបានពីកំណើត។ ខ្ញុំលើកទំនាក់ទំនងក្នុងគ្រួសារមកគិតមុនសិន។ មានអ្នកខ្លះគិតថា ទំនាក់ទំនងក្នុងគ្រួសារមិនសូវសំខាន់ តែបើតាមទ្រឹស្ដីចិត្តវិទ្យា គ្រួសារជាកន្លែងដែលកំណត់ចរិតលក្ខណៈរបស់មនុស្សតាំងពីក្មេង។ អ្វីដែលក្មេងជួបប្រទះក្នុងផ្ទះ នឹងក្លាយជាចរិតរបស់គេនៅថ្ងៃក្រោយ។ តើកន្លែងណាដែលវាមិនសំខាន់នោះ?

មនុស្សចោលម្សៀត ក៏មានគ្រួសារដែរ តែពួកគេមិនសូវមានទំនាក់ទំនងល្អ។ យើងត្រូវដឹងជាមុនសិនថា តើអ្វីដែលបង្កើតឱ្យមានទំនាក់ទំនងល្អ? គឺការយល់គ្នា ការជួយគ្នា និងការរួមចំណែកពង្រឹងគ្រួសារ។

ការយល់គ្នា សំដៅទៅលើសមាជិកក្នុងគ្រួសារ យល់ពីអត្តចរិតគ្នាទៅវិញទៅមក ហើយសម្របខ្លួន និងណែនាំនៅពេលមានអ្វីខុសឆ្គង។ ម្ដាយឪពុក មិនអាចគិតថាខ្លួនត្រូវគ្រប់ពេល ហើយកូនក៏មិនត្រូវគិតថា ឪពុកម្ដាយខុសគ្រប់ពេលដែរ។

ដើម្បីយល់គ្នាបាន គឺត្រូវចំនាយពេលនិយាយគ្នាឱ្យបានច្រើន ហើយដើម្បីនិយាយគ្នាបាន គឺត្រូវចេះពីរបៀបនិយាយ។ ការនិយាយដែលមានរបៀប អាចនាំសមាជិកគ្រួសារស្វែងយល់ពីគ្នាបានកាន់តែរហ័ស និងមិនខាតពេលឈ្លោះប្រកែកគ្នាព្រោះការយល់ច្រឡំ។ វាមិនស្រួលដូចអ្វីដែលខ្ញុំសរសេរទេ។

ឪពុកម្តាយរបស់ខ្ញុំ កើតក្នុងសម័យសង្គ្រាម ហេតុនេះមិនបានរៀនសូត្រជ្រៅជ្រះ។ របៀបនិយាយស្តីរបស់ពួកគេគាត់ តែងតែមានភាពលម្អៀងទៅលើអ្វីដែលគាត់ជឿ។ អ្វីដែលអាក្រក់នោះ គឺអ្វីដែលគាត់ជឿ មិនមានហេតុផលច្បាស់លាស់។

ខ្ញុំកើតចេញមកពីគាត់មែន តែពេលខ្ញុំធំឡើង ខ្ញុំមានការផ្លាស់ប្តូរទាំងការគិត ជំនឿ និងរាងកាយ។ គាត់ត្រូវស្វែងយល់ពីខ្ញុំឡើងវិញ។ ខ្ញុំក៏ត្រូវស្វែងយល់ពីពួកគាត់ឱ្យបានច្រើនជាងមុនដែរ ព្រោះពួកគាត់កាន់តែចាស់។ ការយល់ ត្រូវការពេលវេលា និងតិចនិចមួយចំនួន។ តិចនិចទាំងនេះអាចរកបាននៅលើអ៊ីនធឺណេត ហេតុនេះ ខ្ញុំមិនចាំបាច់ដាក់បញ្ចូលក្នុងសៀវភៅទេ។

ក្រៅពីការយល់គ្នា ត្រូវមានការជួយគ្នាទៀត។ សមាជិកគ្រួសារដែលគិតតែពីខ្លួនឯង ហើយមិនដែលមានចិត្តជួយគ្នា ជាមនុស្សចោលម្សៀត។

យើងមិនអាចនិយាយថា ក្នុងគ្រួសារ គ្មានអ្វីដែលយើងអាចជួយបានសោះនោះទេ។ កិច្ចការកំប៉ិកកំប៉ុកក៏ដោយ បើយើងអាចធ្វើបាន ជួយធ្វើឱ្យរួចទៅ។ ជាពិសេស បើសិនជាឪពុកម្តាយយើងមានអាយុច្រើន ត្រូវឆ្លៀតពេលជួយឱ្យបានច្រើន ទាន់នៅមានឱកាសជួយ។

ក្រៅពីជួយជាកម្លាំង ត្រូវជួយដាស់តឿនគាត់ផង។ កូនដាស់តឿន ឬប្រដៅឪពុកម្តាយ នៅពេលពួកគេធ្វើខុស ឬភ្លេចខ្លួន មិនមែនជាការមើលងាយ ឬជាអំពើបាបអ្វីទេ។ តើយើងធ្វើជាកូនរបៀបណា ដែលបណ្តោយឱ្យឪពុកម្តាយរបស់ខ្លួនឯងធ្វើខុសដោយមិនមាត់អ្វីសោះ?

ខ្ញុំស្តីឱ្យឪពុកម្តាយខ្ញុំមិនតិចទេ ហើយគាត់ក៏ស្តីឱ្យខ្ញុំមិនតិចវិញដែរ។ វាជារឿងល្អដែលយើងធ្វើខុស ហើយមានអ្នកជួយចាំប្រាប់យើង។ ខ្ញុំមិនប្រកាន់នឹងភាសាស្តីឱ្យទេ បើសិនជាអ្វីដែលគាត់ប្រាប់ត្រូវ ហើយមានប្រយោជន៍។ សមាជិកគ្រួសារ មិនគួរប្រកាន់រឿងស្តីឱ្យនោះទេ លើកលែងតែមានការប្រើអំពើហិង្សា ដែលត្រូវតែប្រកាន់។

ការជួយមួយទៀតដែលសំខាន់ គឺលុយ។ កុំភ្លេចពីលុយឱ្យសោះ។ យើងត្រូវជួយតាមអ្វីដែលយើងធ្វើបាន ហើយកុំយកមករំលឹក ព្រោះនេះជាការស្ម័គ្រចិត្តរបស់យើង។ ខ្ញុំកាត់ប្រាក់ខែខ្ញុំពាក់កណ្ដាលឱ្យទៅម៉ាក់ខ្ញុំ ដើម្បីបង់ថ្លៃផ្ទះ។ ពួកគាត់ចង់បានផ្ទះថ្មី ដូច្នេះខ្ញុំមានតែជួយគាត់។ ខ្ញុំបំផ្លាញលុយគាត់មករាប់ឆ្នាំទៅហើយ ជួយគាត់វិញខ្លះ ក៏មិនទាស់អ្វីដែរ។

ខ្ញុំមិនចោលម្សៀតក្នុងទំនាក់ទំនងគ្រួសារទេ តែខ្ញុំចោលម្សៀតក្នុងរឿងស្នេហា។ ចំណុចនេះ គឺសម្រាប់មនុស្សប្រុសគ្រប់គ្នា។ គ្មានមនុស្សស្រីណាចង់បាន មនុស្សចោលម្សៀតមកធ្វើជាគូជីវិតទេ។

ត្រង់នេះ ជាចំណុចមានប្រៀបរបស់មនុស្សស្រីដែរ។ បើសិនជាមនុស្សស្រីម្នាក់ចោលម្សៀត តែបានរៀបការនឹងមនុស្សប្រុសដែលជោគជ័យ គេក៏ក្លាយជាមនុស្សជោគជ័យដែរ។ ការរៀបការត្រូវ ក៏ចាត់ទុកជាជោគជ័យមួយក្នុងជីវិតមនុស្សស្រីដូចគ្នា។ ប៉ុន្តែបើមនុស្សប្រុសចោលម្សៀតវិញ បានរៀបការជាមនុស្សស្រីដែលជោគជ័យ គេនឹងកាន់តែចោលម្សៀតលើសដើម។ ការប្រមាថគ្រប់យ៉ាង នឹងធ្លាក់ទៅលើខ្លួនគេ។

ខ្ញុំយកអ្វីដែលសង្សារខ្ញុំនិយាយមកគិតឡើងវិញ ហើយគិតពីអ្វីដែលខ្ញុំធ្លាប់ធ្វើ ទើបខ្ញុំអាចបញ្ជាក់ខ្លួនឯងថា ពិតជាចោលម្សៀតមែន។ ខ្ញុំនិយាយចោលច្រើនណាស់។ លុយក៏រកមិនបានច្រើន អំណាចក្នុងសង្គមក៏គ្មាន ហេតុនេះខ្ញុំមិនចម្លែកចិត្តទេដែលសង្សារខ្ញុំមិនជឿលើខ្ញុំ។

មនុស្សស្រី អាចមើលដឹងពីភាពចោលម្សៀតរបស់មនុស្សប្រុសបាន។ គ្រាន់តែពេលខ្លះ ពួកគេអាចនៅមានចិត្តស្រលាញ់ ហើយមិនអាចបែងចែកល្អ និងអាក្រក់បានប៉ុណ្ណោះ។ នៅពេលដែលចែកបាន ហើយចិត្តស្រលាញ់ធ្លាក់ចុះ ពួកគេអាចដកខ្លួនបានដោយគ្មានអ្វីត្រូវស្ដាយទេ។ មនុស្សចោលម្សៀត ជាប្រភេទមនុស្សដែលគេមិនស្ដាយក្រោយ និងមិនយកមករំលឹកក្រោយពេលបែកគ្នា។

ខ្ញុំធ្លាប់អានពត៌មានអំពីប្តីដែលអត់មានលុយឱ្យប្រពន្ធឆ្លងទន្លេ ឬឱ្យប្រពន្ធធ្វើការលំបាកដើម្បីរកលុយចិញ្ចឹមខ្លួនឯង។ ពីមុន ខ្ញុំគិតថា ទាល់តែបែបនោះ ទើបហៅថាបោលម្សៀត។ មនុស្សប្រុសរបៀបនោះ គឺបោលម្សៀតក្នុងកម្រិតផ្សេង ហើយខ្ញុំបោលម្សៀតក្នុងកម្រិតផ្សេងទៀត។ ចំណុចរួម គឺស្ថិតក្នុងប្រភេទតែមួយ។

# ៥ សុខភាព

យើងមិនអាចស្មានដឹងថា យើងឈឺនៅពេលណាទេ ប៉ុន្តែនៅពេលដែលយើងឈឺ យើងក្លាយជាមនុស្សបោលម្សៀតហើយ។ ទោះបីយើងមិនអាចគ្រប់គ្រងវាបាន ក៏មិនមែនបានន័យថា យើងមិនមានកំហុសនោះទេ។

សុខភាព ជាកត្តាសំខាន់ជាងគេសម្រាប់មនុស្ស។ បើសុខភាពអន់ អ្វីក៏មិនបាច់សង្ឃឹមថាធ្វើបានដែរ។ សុខភាពចែកចេញជាពីរ គឺផ្លូវកាយ និងផ្លូវចិត្ត។ ផ្លូវភេទស្ថិតនៅក្នុងផ្លូវកាយផង និងផ្លូវចិត្តផង ដូច្នេះខ្ញុំមិនចែកវាចេញទេ។

យើងចាប់ផ្តើមពីសុខភាពផ្លូវកាយជាមុនសិន។ តើយើងមានកម្លាំងខ្សោយដែរទេ? តើយើងមានជំងឺរ៉ាំរ៉ៃដែរទេ? តើយើងខ្សោយផ្លូវភេទដែរទេ? បើសិនជាមាន យើងជាមនុស្សបោលម្សៀតក្នុងផ្នែកសុខភាពហើយ។

កុំភ្លេច “បោលម្សៀត” បានន័យថា គ្មានប្រយោជន៍ ឬមិនកើតការ។ បើសុខភាពយើងមិនកើត កុំបន្ទោសគេ។

ខ្ញុំមានសុខភាពផ្លូវកាយមិនសូវល្អទេ។ ខ្ញុំមានជម្ងឺជាប់ខ្លួន ហើយពេលណាដែលវាធ្វើទុក្ខ ខ្ញុំត្រូវរត់ទៅរកពេទ្យជានិច្ច។ ខ្ញុំធាត់ ព្រោះខ្ជិលហាត់ប្រាណ និងចូលចិត្តរបស់ផ្អែម។

សុខភាពផ្លូវចិត្ត ជាអ្វីដែលយើងមិនសូវអើពើ ព្រោះយើងគ្មានចំណេះដឹងក្នុងផ្នែកនោះ។ ពេលអ្នកណាម្នាក់មានបញ្ហាផ្លូវចិត្ត យើងនឹងនាំគ្នាទៅរកគ្រូទាយ ដើម្បី

សម្រួលគ្នាជាមួយព្រលឹងខ្មោចដែលយើងជឿថា បានធ្វើអ្វីមកលើម្នាក់នោះ។ ជំនឿបំផ្លាញចំណេះដឹង ហើយធ្វើឱ្យយើងគ្មានបំណងចង់ស្វែងយល់ពីវា។

យើងមិនទាន់មានមិនអីទេ តែពេលដែលយើងមានហើយ យើងលែងជាខ្លួនយើងទៀតផង។ ជីវិតរបស់យើងនឹងចប់ ត្រឹមវង្វេងក្នុងផ្លូវចិត្ត។ ជម្ងឺផ្លូវចិត្ត ក៏ជាមូលហេតុមួយក្នុងចំណោមមូលហេតុដទៃទៀតដែលធ្វើឱ្យធ្លាក់ក្នុងភាពក្រីក្រដែរ។ ជម្ងឺផ្លូវចិត្តខ្លះ អាចនាំឱ្យមនុស្សគិតខ្លី បញ្ចប់ជីវិតខ្លួនឯងទៀតផង។

សាសនា ក៏អាចជាកត្តានាំឱ្យមានជម្ងឺផ្លូវចិត្តដែរ។ សម្រាប់ខ្ញុំ អ្នកដែលមានជំនឿលើសាសនា ហើយបដិសេធវិទ្យាសាស្ត្រ សុទ្ធតែជាមនុស្សដែលមានរោគចិត្ត។ ខ្ញុំមិនរាប់អ្នកដែលធ្វើពុតជាជឿសាសនាដើម្បីបានប្រយោជន៍នោះទេ ព្រោះពួកគេគ្មានជម្ងឺអ្វីទាំងអស់ ក្រៅពីចិត្តលោភលន់ និងចូលចិត្តដើរផ្លូវកាត់។

មិនថាយើងមានបញ្ហាសុខភាពមួយណាទេ យើងជាមនុស្សបោលម្សៀតដូចគ្នា។

# សរុប

មនុស្សបោលម្សៀតមាន ៥ប្រភេទ៖

១ ការអប់រំ និងចំនេះដឹង
២ ហិរញ្ញវត្ថុ
៣ អាជីព
៤ គ្រួសារ និងស្នេហា
៥ សុខភាព

សាកគិតខ្លួនឯងទៅមើល ថាយើងបោលម្សៀតក្នុងផ្នែកណាខ្លះនៃជីវិត។ ខ្ញុំដឹងខ្លួនខ្ញុំហើយ។

# មនុស្សចោលម្សៀត និង បទពិសោធន៍

បទពិសោធន៍ ជាអ្វីដែលយើងធ្លាប់ឆ្លងកាត់។ អ្នកដែលមានបទពិសោធន៍ល្អ ច្រើនតែក្លាយជាមនុស្សដែលមានសង្ឃឹមក្នុងជីវិត និងមើលគ្រប់យ៉ាងក្នុងផ្លូវវិជ្ជមាន។ អ្នកដែលមិនធ្លាប់វិញ ពួកគេអាចនឹងក្លាយជាមនុស្សចោលម្សៀត។ អ្នកសរសេរប្លុក Tim Denning បានពន្យល់ថា “ភាពចោលម្សៀត ត្រូវបានបង្កើតឡើង នៅពេលមនុស្សម្នាក់ជួបនឹងការបរាជ័យធំ ឬធ្លាក់ចុះដល់ចំណុចសូន្យនៃជីវិត”។

យើងមិនអាចប្រកែកបានទេថា បទពិសោធន៍គ្មានឥទ្ធិពលសោះលើមនុស្ស។ នៅមានកត្តាជម្រុញមួយទៀត ដែលជួយឱ្យមនុស្សយកបទពិសោធន៍មកសង្កត់ខ្លួនឯង គឺការបកប្រែន័យរបស់បទពិសោធន៍នោះ។

យើងអាចមើលឧទាហរណ៍ពីមនុស្សជាប់គុក ពីរនាក់។ ម្នាក់ងើយមើលទៅលើមេឃតាមបង្អួច ឃើញពន្លឺផ្កាយភ្លឺពេញមេឃ។ គេក៏យល់ថា ជីវិតរបស់គេនៅមានភាពស្រស់បំព្រង។ ម្នាក់ទៀត ឱនមុខចុះមើលទៅភក់ជ្រាំ ហើយគិតថា ជីវិតរបស់គេត្រូវបានលុបចោល។ ពួកគេជួបរឿងដូចគ្នា និងនៅក្នុងកន្លែងតែមួយ តែការបកប្រែ ធ្វើឱ្យពួកគេមើលមកកាន់ជីវិតខ្លួនឯងខុសគ្នាទៅវិញ។

ឥលូវយើងដឹងហើយ មនុស្សចោលម្សៀត កើតឡើងព្រោះអ្វីដែលគេឆ្លងកាត់ និងរបៀបដែលគេបកប្រែបទពិសោធន៍ផ្ទាល់ខ្លួន។ ខ្វះអី កូនអ្នកក្រ ដែលគ្មានវាសនាបានចូលរៀនត្រឹមត្រូវ តែអាចកែប្រែជីវភាពខ្លួនឯងឱ្យក្លាយជាអ្នកមានបាន។ កូនអ្នកក្រ ដែលបន្តភាពក្រីក្រ ក៏មានមិនតិចដែរ។

បទពិសោធន៍ដែលខ្ញុំមាន មិនអាក្រក់ដល់ថ្នាក់សុំទានគេទេ តែវាក៏មិនល្អដែរ។ ខ្ញុំត្រូវបញ្ជូនទៅរៀនក្នុងសាលាកូនអ្នកមាន ហើយត្រូវគេមើលងាយ ហេតុនេះ ខ្ញុំគិតថា ការមើលងាយ ជាសារជាតុរបស់មនុស្ស។ ពេលខ្ញុំធំឡើង ការស្អប់របស់ខ្ញុំក៏កាន់តែធំដូចគ្នា។ អ្វីដែលខ្ញុំជួប ក្លាយជាហេតុផលដែលខ្ញុំប្រើដើម្បីស្អប់អ្នកដទៃ។ ខ្ញុំគិតថា បើខ្ញុំមានហេតុផល គឺខ្ញុំត្រូវហើយ។ វាអាចត្រូវ តែវាក៏អាចធ្វើឱ្យខ្ញុំក្លាយជាមនុស្សចោលម្សៀតដែរ។

ខ្ញុំមានមិត្តភក្តិមិនដល់ដប់នាក់ទេ ព្រោះខ្ញុំពិបាកជឿអ្នកដទៃ។ ខ្ញុំខ្លាចបើសិនជាស្និទ្ធស្នាលជាមួយគេពេក គេអាចនឹងក្បត់ខ្ញុំនៅថ្ងៃណាមួយ។ បើខ្ញុំមិនទុកគេជាមិត្តភក្តិ ទោះបីជាគេធ្វើដាក់ខ្ញុំយ៉ាងម៉េច ក៏ខ្ញុំមិនពិបាកដោះស្រាយដែរ។

មិត្តភក្តិដែលខ្ញុំមាន ក៏មិនសូវរវល់ជាមួយខ្ញុំដែរ ព្រោះគេមើលឃើញពីភាពចោលម្សៀតរបស់ខ្ញុំ។ ខ្ញុំនៅតែនិយាយពីបំណងបើកហាងលក់សៀវភៅដោយខ្លួនឯងប្រាប់ពួកគេជានិច្ច។ មកទល់ពេលនេះ អ្វីក៏ខ្ញុំមិនបានធ្វើដែរ។ មិត្តភក្តិនៅតែជាមិត្តភក្តិ ព្រោះគេមិនដាច់ចិត្តកាត់ចោលមិត្តភាព តែពួកគេគ្មានសង្ឃឹមអ្វីមកលើខ្ញុំទៀតទេ។ មិត្តភាពក្នុងទីងងឹត មិនដឹងថាគេរាប់អានយើងព្រោះអ្វី។

ខ្ញុំធ្លាប់ទិញសៀវភៅមកលក់ តែលក់មិនដាច់ ហេតុនេះខ្ញុំក៏បិទចោល ហើយរាប់វាជាការបរាជ័យរបស់ខ្ញុំ។ ខ្ញុំមិនហ៊ានបោះពុម្ពសៀវភៅខ្លួនឯងលក់ ព្រោះខ្លាចមិនដើរម្តងទៀត។ បទពិសោធន៍ដែលខ្ញុំមាន មិនបានជួយអ្វីទេ ក្រៅពីប្រាប់ខ្ញុំថា ធ្វើជាមនុស្សចោលម្សៀតបន្តទៀតទៅ។

បរាជ័យដែលខ្ញុំមាន មិនសូវធ្ងន់ធ្ងរទេ តែវាមានច្រើន ហេតុនេះខ្ញុំគិតថា  ជីវិតខ្ញុំ ជាភាពបរាជ័យ។ មិនថាខ្ញុំបោះបង់ចោល ឬមិនបោះទេ ខ្ញុំនៅតែជាមនុស្សចោលម្សៀតដដែល។

# តើខ្ញុំត្រូវធ្វើអ្វីបន្តទៀត?

ឥលូវខ្ញុំដឹងថា ខ្ញុំជាមនុស្សចោលម្សៀតហើយ ហេតុនេះខ្ញុំមានជម្រើសពីរយ៉ាង គឺ បន្តបដិសេធភាពចោលម្សៀតរបស់ខ្លួនឯង និងរកវិធីដោះស្រាយ។

ជម្រើសទីមួយ ងាយជាង ហើយប្រើបានផលភ្លាមទៀតផង។ បើខ្ញុំបដិសេធថាខ្លួនខ្ញុំមិនមែនជាមនុស្សចោលម្សៀត ខ្ញុំអាចត្រលប់ទៅគិតថា ខ្លួនឯងជោគជ័យក្នុងរឿងបន្តិចបន្តួច ហើយដើរអួតគេអួតឯង។ ដល់ពេលមួយដែលខ្ញុំបរាជ័យខ្លាំងមែនទែន ខ្ញុំនឹងអស់អ្វីបដិសេធ ហើយជីវិតខ្ញុំនឹងត្រូវចប់មិនខាន។

ជម្រើសទីពីរ គឺខ្ញុំត្រូវដោះស្រាយតាមផ្នែកដែលខ្ញុំចោលម្សៀត។ ខ្ញុំនឹងចាប់ផ្ដើមពីសុខភាពទៅមុន។ បន្ទាប់មក គឺហិរញ្ញវត្ថុ។ បន្ទាប់មកទៀត គឺអាជីព។ ហើយចុងក្រោយ គឺស្នេហា។ ខ្ញុំមិនមែនមិនឱ្យតម្លៃស្នេហាទេ តែខ្ញុំត្រូវកាត់បន្ថយភាពចោលម្សៀតចេញសិន ទើបខ្ញុំអាចធ្វើបានបន្តទៀតក្នុងរឿងស្នេហា។

ខ្ញុំរើសយកជម្រើសទីពីរ ព្រោះខ្ញុំមិនចង់នៅជាមនុស្សចោលម្សៀត។ ខ្ញុំត្រូវស្មោះត្រង់នឹងខ្លួនឯង ហើយបន្ទោសខ្លួនឯងលើអ្វីដែលកើតឡើង។ ខ្ញុំបន្ទោសដោយមានវិធីដោះស្រាយ។

មនុស្សចោលម្សៀត ប្រៀបដូចជាអ្នកជម្ងឺដែលមិនចេះជាដាច់។ បើសិនជាយើងភ្លេចខ្លួនតែបន្តិច យើងនឹងត្រលប់មកសភាពដើមវិញ។ ខ្ញុំមិនដឹងថាខ្ញុំអាចធ្វើបានឬអត់ទេ តែខ្ញុំគួរតែសាកល្បង។ ខ្ញុំធុញនឹងពាក្យថា “ចោលម្សៀត” ហើយយើងគ្រប់គ្នាក៏គួរតែធុញនឹងពាក្យនេះដែរ។

បើសិនជាមានបំណងចង់ជួយខ្ញុំឱ្យចេញផុតពីភាពចោលម្សៀត អាច
ជួយទិញសៀវភៅផ្សេងទៀតរបស់ខ្ញុំបាន

តាមរយៈលេខទូរស័ព្ទ ០១៥ ២១ ៤៤ ៣២